# កិច្ចព្រមព្រៀងប៉ារីស ថ្ងៃ២៣តុលាឆ្នាំ១៩៩១

# ការរំដោះប្រទេសកម្ពុជា និង បដិវត្តន៍ផ្កាឈូក!

*បងប្អូនរួមជាតិជាទីគោរព*

*ខាងក្រោមនេះ ជាសេចក្ដីដកស្រង់ នៃកិច្ចព្រមព្រៀងទីក្រុង ប៉ារីស ថ្ងៃទី២៣តុលាឆ្នាំ១៩៩១ ដើម្បី ដោះស្រាយ វិវាទ នៅកម្ពុជា តាម នយោបាយពិភពលោក ។*

រដ្ឋនានា ដែលបានចូលរួមក្នុង សន្និសិទក្រុងប៉ារីស ស្ដីពីប្រទេសកម្ពុជា មានជាអាទិ ប្រទេស អូស្ត្រាលី ប្រ៊ុយណេ ដារូសាឡឹម កម្ពុជា កាណាដា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋបារាំង សាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋ ឥណ្ឌូណេស៊ី ជប៉ុន សាធារណរដ្ឋ ប្រជាមានិតលាវ ម៉ាឡេស៊ី សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសាំងហ្គាពួរ រ ាជាណាចក្រ ថៃឡង់ សហភាព សង្គមនិយមសូវៀត រាជណាចក្រអង់គ្លេសនិងអៀរឡង់ខាងជើង សហរដ្ឋអាមេរិក សាធារណរដ្ឋសង្គមនិយម វៀតណាម និង សាធារណរដ្ឋ សហពន្ធសង្គមនិយម យូហ្គោស្លាវី

នៅចំពោះវត្តមាន នៃលោក អគ្គលេខាធិកានៃអង្គការសហប្រជាជាតិ

ដើម្បី ថែរក្សា ការពារ អធិបតេយ្យភាព ឯករាជភាព និង បូរណភាពដែនដី និង ភាពមិនអាចរំលោភបំពានបាននៃដែនដី អព្យាក្រិតភាព និង ឯកភាពជាតិកម្ពុជា

ដោយមានបំណង រៀបចំ និង ការពារឱ្យមានសន្តិភាពជាថ្មី នៅកម្ពុជា ដើម្បីជំរុញឱ្យមានការផ្សះផ្សារជាតិ និងធានាឱ្យប្រជាពលរដ្ឋខ្មែរប្រើសិទ្ធិស្វ័យសំរេច តាមរយៈ ការបោះឆ្នោតដោយសេរីនិងសមធម៌

ដោយជឿជាក់ថា មានតែដំណោះស្រាយនៃវិវាទខ្មែរ តាមរយៈនយោបាយពិភពលោក តែមួយគត់ ដែលនឹងមានយុត្តិធម៌ ថិតថេរ ជាយូរអង្វែង ហើយ នឹងអាចជាវិភាគទាន ជួយចូលរួមឱ្យ មានសន្តិភាពតំបន់ និង អន្តរជាតិ និង សន្តិសុខ

ដោយយល់ស្របលើ ឯកសារជាក្របខណ្ឌ នាថ្ងៃ២៨សីហា១៩៩០ ដែលត្រូវបាន ទទួលយក ទាំងស្រុង ដោយ ភាគីខ្មែរមកធ្វើជាមូលដ្ឋាន ដើម្បីដោះស្រាយវិវាទនៅកម្ពុជា ហើយ ដែលបន្ទាប់មក ត្រូវបានអនុម័តយល់ព្រមជាឯកច្ឆ័ន្ទ ដោយ សេចក្តីសំរេច លេខ៦៦៨ ថ្ងៃ២០កញ្ញា ឆ្នាំ១៩៩០ និង សេចក្តីសំរេចដោយ មហាសន្និបាត អសប ៤៥/៣ នៃ ថ្ងៃ ១៥តុលា ឆ្នាំ១៩៩០

ដោយកត់សំគាល់ពីការបង្កើតនៃ ឧត្តមក្រុមប្រឹក្សា ជាតិកម្ពុជា ថា ជាស្ថាប័នត្រឹមត្រូវតែមួយគត់ តំណាងឱ្យកម្ពុជានៅក្រៅប្រទេស ក្នុងពេលអន្តរកាល និង ជាប្រភព នៃអំណាច នៅប្រទេសកម្ពុជា ដែលនៅ ក្នុងពេលនេះដែរ អធិបតេយ្យភាពជាតិ និង ឯកភាពជាតិ គឺជារបស់ពិសិដ្ឋ។

ដោយយល់ស្របលើការជ្រើស រើសជាឯកច្ឆ័ន្ទ នៅប៉េកាំង ថ្ងៃ១៧ កក្កដា១៩៩១ នៃ សម្តេចសីហនុ ឱ្យធ្វើ ជា ប្រធាននៃ ឧត្តមក្រុមប្រឹក្សជាតិ។

ដោយទទួលស្គាល់ថា ការពង្រឹងមុខនាទីនៃ អសប តំរូវឱ្យមានការបង្កើតនូវ អាជ្ញាធមិអសប អន្តរកាល មួយនៅកម្ពុជា (អាប្រូនិច ឬ អ៊ុនតាក់)ដែលមាន សមាសភាពជាស៊ីវិល និង យោធា ដែលនឹងបំពេញសកម្មភាព ក្នុង ការគោរព ទាំងស្រុង នៃអធិបតេយ្យភាពនៃប្រទេសកម្ពុជា។

ដោយកត់សំគាល់លើសេចក្តីថ្លែងការនានា បន្ទាប់ពីអង្គប្រជុំ នៅទីក្រុងជ្យាកាតា ថ្ងៃ៩ -១០ កញ្ញា ១៩៩០ នៅប៉ារីស ថ្ងៃទី២១-២៣ ធ្នូ ១៩៩០ នៅប៉ាតាយ៉ាថ្ងៃ២៤-២៦ មិថុនា១៩៩១ នៅប៉េកាំងថ្ងៃទី១៦-១៧ កក្កដា១៩៩១ នៅប៉ាតាយ៉ា ថ្ងៃ២៦-២៩សីហា១៩៩១ ព្រមទាំងកិច្ចប្រជុំ នៅជ្យាការតា ថ្ងៃ៤-៦ មិថុនា ១៩៩១ និង នៅញូវយ៉ក ថ្ងៃ១៩កញ្ញា ១៩៩១។

ដោយយល់ស្របលើ សេចក្តីសំរេច ៧១៧ នៃ ក្រុមប្រឹក្សាសន្តិសុខនៃ អសប ថ្ងៃ១៦តុលា១៩៩១ ស្តីពីប្រទេសកម្ពុជា។

ដោយទទួលស្គាល់ថាប្រវត្តិសាស្រ្តប្រកបដោយសោកនាដកម្មថ្មីៗនៃប្រទេសកម្ពុជា តំរូវឱ្យមាវិធានការ ពិសេសសំរាប់ធានា ការពារសិទ្ធិមនុស្ស និង មិនឱ្យមានការវិលត្រឡប់មកវិញ នៃ នយោបាយនិងការប្រព្រឹត្តិ នានា ក្នុងអតីតកាល។

*បានព្រមព្រៀងសំរេចដូចតទៅនេះ:*

ជំពូក១

១ , ប្រទេសកម្ពុជាសន្យាជាឧឡារិកតាមកិច្ចព្រមព្រៀងនេះ ថានឹងបន្តថែរក្សា និង ការពារអធិបតេយ្យភាព ឯករាជ្យភាព បូណ៌ភាព និង ភាពមិនអាចរំលោភ បាននៃទឹកដី អព្យាក្រឹតភាពនិងឯកភាពជាតិ។ អព្យាក្រឹតភាពជានិច្ចនិរន្តនៃប្រទេស

កម្ពុជានឹងត្រូវ ប្រកាស ចារទុកជា ពិសិដ្ឋដោយ រដ្ឋធម្មនុញ្ញខ្មែរដែលនឹង ត្រូវអនុម័តក្រោយពីការបោះ ឆ្នោតដោយសេរីនិងយុត្តិធម៌។

២, ដើម្បីសំរេចបាននូវគោលដៅនេះ ប្រទេសកម្ពុជា សន្យាថា :

ឃ , នឹងប្រកាសលុបចោលនូវសន្ធិសញ្ញានិងកិច្ចព្រមព្រៀងនានាដែលមិនស្របនិងមិនគោរពអធិបតេយ្យភាព ឯករាជ្យភាព បូណ៌ភាព និង ភាពមិន អាចរំលោភបាន នៃដែនដី អព្យាក្រឹតភាព និងឯកភាពជាតិនៃប្រទេសកម្ពុជា។

## ជំពូក២

១, ភាគីដទៃទៀតនៃកិច្ចព្រមព្រៀងនេះសន្យាជាឧឡារិកថានឹងទទួលស្គាល់និងគោរពគ្រប់បែបយ៉ាងនូវអធិបតេយ្យភាព ឯករាជ្យភាព បូណ៌ភាព និង ភាពមិន អាចរំលោភបាន នៃដែនដី អព្យាក្រឹតភាព និងឯកភាពជាតិនៃប្រទេសកម្ពុជា។

២, ដើម្បីសំរេចបាននូវគោលដៅនេះ ភាគីទាំងអស់ សន្យាថា :

ង , ជៀសវាង មិនប្រើដែនដីខ្លួន ឬដែនដីប្រទេសដទៃទៀតដើម្បីធ្វើឲ្យប៉ះពាល់នូវ អធិបតេយ្យភាព ឯករាជភាព បូណ៌ភាព និង ភាពមិន អាចរំលោភបាន នៃដែនដី អព្យាក្រឹតភាព និងឯកភាពជាតិនៃប្រទេសកម្ពុជា។

## ជំពូក៣

១, បុគ្គលទាំងអស់ដែលរស់នៅក្នុងប្រទេសកម្ពុជា នឹងត្រូវទទួលបានការគោរព និងគាំពារ សិទ្ធិនិងសេរីភាពដែលមានចែងក្នុងសេចក្តីប្រកាសជា សាកល នៃសិទ្ធិមនុស្ស និង ក្នុងឧបករណ៍ជាក់ស្តែងទាក់ទងទៅនឹងសិទ្ធិមនុស្ស។

២, ដើម្បីសំរេចបាននូវគោលដៅនេះ ប្រទេសកម្ពុជា សន្យាថា :

- ធ្វើយ៉ាងណាឲ្យមានការគោរពសិទ្ធិមនុស្សនិងសេរីភាពជាគ្រឹះនានា នៅ ប្រទេសកម្ពុជា។
- គាំទ្រសិទ្ធិនៃប្រជាពលរដ្ឋខ្មែរទាំងអស់ ដែលខំ ផ្តួចផ្តើមធ្វើសកម្មភាពនានា ដើម្បីបណ្តុះបណ្តាលលើកស្ទួយ និងការពារសិទ្ធិមនុស្ស និង សេរីភាព ជាគ្រឹះទាំងនេះ។
- ចាត់វិធានការណ៍ឲ្យមានប្រសិទ្ធិភាព ដើម្បីធ្វើយ៉ាងណាធានា មិនឲ្យមាននយោបាយនិងការប្រព្រឹត្តអំពើនានាដូច ក្នុងអតីតកាល អាចវិល ត្រឡប់មកវិញ។
- សុំចូលរួមជាសមាជិកក្នុងឧបករណ៍អន្តរជាតិជាក់ស្តែងដែលទាក់ទងសិទ្ធិមនុស្ស។
- ហត្ថលេខីដទៃទៀតនៃកិច្ចព្រមព្រៀងនេះ សន្យាថានឹងជួយបណ្តុះបណ្តាលនិងលើកទឹកចិត្ត នូវការគោរពសិទ្ធិមនុស្ស និង សេរីភាពជា គ្រឹះនានា នៅប្រទេស កម្ពុជា ដូចដែលមានចែង ទាក់ទងនៅ ក្នុងឧបករណ៍ អន្តរជាតិ និង ក្នុងសេចក្តីសំរេចជាក់ស្តែងនានារបស់មហាសន្និបាត នៃ អង្គការសហ ប្រជាជាតិ ដើម្បីទប់ជាអាទិកុំឲ្យមានការរំលោភលើសិទ្ធិមនុស្ស ជារឿយៗ ច្រំដែលតទៅទៀត។

## ជំពូក៤

១, ភាគីនានានៃកិច្ចព្រមព្រៀងនេះ សុំស្នើឲ្យរដ្ឋទាំងអស់ ទទួលស្គាល់និងគោរពគ្រប់បែបយ៉ាង នូវអធិបតេយ្យភាព ឯករាជ្យភាព បូណ៌ភាព និង ភាពមិន អាចរំលោភបាន នៃទឹកដី អព្យាក្រឹតភាព និង ឯកភាពជាតិនៃប្រទេសកម្ពុជា និង មិនធ្វើសកម្មភាពអ្វីទាំងអស់ដែល មានន័យ ផ្ទុយប្រឆាំងមិនស្របគោលការណ៍ ឬគំនិតដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ។

## ជំពូក៥

១, ក្នុងករណីមានការឈ្លានពាន ឬ ព្រមាន ថានឹងមានការឈ្លានពាន មកលើអធិបតេយ្យភាព ឯករាជភាព បូរណភាព និង ភាពមិន អាចរំលោភបាន នៃដែនដី អព្យាក្រឹតភាព និង ឯកភាពជាតិនៃប្រទេសកម្ពុជា ឬ ក្នុងករណី មានការរំលោភ លើកិច្ចសន្យាណាមួយ ក្នុងកិច្ច ព្រមព្រៀងនេះ ភាគី ទាំងអស់ នៃកិច្ចព្រមព្រៀង សន្យាថានឹងធ្វើកាពិគ្រោះគ្នាជាបន្ទាន់ ដើម្បីចាត់វិធាន ការសមស្រប ដើម្បីឱ្យមាន ការគោរពកិច្ចសន្យា នេះ ឡើងវិញ តាម មធ្យោបាយសន្តិវិធី ។

២, ក្នុងចំណោមវិធានការទាំងនេះ អាចមានការប្តឹងទៅដល់ក្រុមប្រឹក្សាសន្តិសុខ នៃអង្គការសហប្រជាជាតិ ឬ តាមរយៈការប្រើ មធ្យោបាយដោះស្រាយជំលោះបែបសន្តិវិធី ដូចមានចែងក្នុង ជំពូក៣៣ នៃ ធម្មនុញ្ញអង្គការសហប្រជាជាតិ ។

៣, ភាគីនៃកិច្ចព្រមព្រៀងនេះ អាចសុំជំនួយការផងដែរពី សំណាក់សហប្រធាននៃកិច្ចប្រជុំទីក្រុងប៉ារីស ស្តីពីប្រទេសកម្ពុជា ។

៤, ក្នុងករណីមានការរំលោភយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ភាគីនៃកិច្ចព្រមព្រៀងនេះ ត្រូវស្នើសុំ ទៅអង្គការមានសមត្ថកិច្ច នៃអង្គការសហប្រជាជាតិ ឱ្យចាត់វិធានការសមស្របជាពិសេសដទៃទៀត ដើម្បីហាមឃាត់និង បញ្ចប់នូវការរំលោភ ទាំងអស់នេះ ស្របតាម ឧបករណ៍អន្តរជាតិ ជាទំនាក់ទំនងជាក់ស្តែង ។

ជំពូក៦

កិច្ចព្រមព្រៀងនេះ នឹងចូលជាធរមាន នៅថ្ងៃចុះហត្ថលេខា ។

ជំពូក៧

កិច្ចព្រមព្រៀងបច្ចុប្បន្ននេះ នឹងនៅតែបើកចំហរឱ្យរដ្ឋទាំងអស់ចូលរួម ។ ឧបករណ៍នៃការចូលរួមនឹង ត្រូវតំកល់ទុកអមរដ្ឋាភិបាល សាធារណរដ្ឋបារាំង និង សាធារណរដ្ឋឥណ្ឌូណេស៊ី ។ ចំពោះរដ្ឋណាដែលចូលរួមក្នុងកិច្ចព្រមព្រៀងនេះ កិច្ចព្រមព្រៀង នឹងចូលជាធរមាន នៅថ្ងៃដាក់ដំកល់ឧបករណ៍ចូលរួមនេះ ។

ជំពូក៨

ទំរង់ដើមនៃកិច្ចព្រមព្រៀងបច្ចុប្បន្ននេះ ដែលសរសេរជាអក្សរ អង់គ្លេស ចិន បារាំង ខ្មែរ និង រុស្ស៊ី ត្រូវចាត់ទុកយក ជាបានការ ហើយនឹងត្រូវ តំកល់ទុកនៅ អមរដ្ឋាភិបាលសាធារណរដ្ឋបារាំង និង សាធារណរដ្ឋឥណ្ឌូណេស៊ី ដែលនឹង ផ្ញើ សេចក្តីចំលងបញ្ជាក់ ថា ពិតជា ស្របតាម ត្រឹមត្រូវ ផ្ញើជូនទៅឱ្យរដ្ឋាភិបាលនៃរដ្ឋដទៃទៀតដែលបាន ចូលរួម ក្នុង សន្និសិទ ក្រុងប៉ារីស ស្តីពីប្រទេស កម្ពុជា និង ទៅជូនលោក អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

អាស្រ័យហេតុនេះ ហត្ថលេខីពេញសមត្ថភាព ខាងក្រោម ដែលបានទទួលការអនុញ្ញាតិពេញច្បាប់ ក៏បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងបច្ចុប្បន្ននេះ ។

*ធ្វើនៅទីក្រុងប៉ារីស ថ្ងៃ២៣តុលាឆ្នាំមួយពាន់ប្រាំបួនរយកៅសិបមួយ ។*

,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,

សង្ខេប

ជំពូក១ ប្រទេសកម្ពុជាត្រូវលុបសន្ធិសញ្ញានានាចោលដើម្បីការពារអធិបតេយ្យភាពរបស់ខ្លួន ។

ជំពូក២ ប្រទេសហត្ថលេខីដទៃទៀតមាន យួននិងសៀម ត្រូវតែគោរពអធិបតេយ្យភាពខ្មែរ ។

ជំពូក៣ ប្រទេសកម្ពុជាត្រូវគោរពសិទ្ធិមនុស្ស ។

ជំពូក៤ ប្រទេសហត្ថលេខីមិនត្រូវបណ្តោយឱ្យប្រទេសណាមួយរំលោភប្រទេសកម្ពុជាទេ ។

ជំពូក៥ ក្នុងករណីឈ្លានពានទឹកដីនិងរំលោភសិទ្ធិមនុស្ស ប្រទេស ហត្ថលេខី និង សហប្រធាន ត្រូវចាត់វិធានការដើម្បីដោះស្រាយដោយ សន្តិវិធី ឬត្រូវ ប្តឹងទៅអង្គការសហប្រជាជាតិនិងក្រុមប្រឹក្សាសន្តិសុខនៃ អង្គការសហប្រជាជាតិ។

,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,

## *បងប្អូនរួមជាតិជាទីគោរព*

២១ឆ្នាំមកហើយ ដែលប្រជាពលរដ្ឋខ្មែរពុំទាន់បានឃើញនូវ ការលុបចោល នៃសន្ធិសញ្ញា ទ្វេភាគី ១៩៧៩-១៩៨២-១៩៨៣-១៩៨៥ នៅឡើយទេ។ ផ្ទុយទៅវិញ គេមានការខកចិត្តជាខ្លាំងលើការអនុម័ត យក សន្ធិសញ្ញា បំពេញបន្ថែម ២០០៥ ក្រោមការ គាប សង្កត់ នៃបក្សប្រជាជនហ៊ុនសែន ដើម្បីបន្តសុពលភាព និង ពង្រឹង សន្ធិសញ្ញា អសមភាព និង អយុត្តិធម៌ពីមុន ដើម្បី ពង្រឹង អាណាព្យាបាល និងការកាត់យក ទឹកដីទៅឱ្យប្រទេសយួន។ ដោយយោង ទៅលើ សន្ធិសញ្ញា ទាំង នេះ និង ដោយសារ ច្បាប់ អនុក្រិត និង វិធានការរដ្ឋបាល ទ្វេភាគីនានា ដែលចេញមកពីពី សន្ធិសញ្ញា ទាំងនេះ ប្រទេស យៀកណាម បានជាន់ឈ្លី លើ អធិបតេយ្យ ភាព ឯករាជភាព បូរណភាពទិកដី កម្ពុជា ហាក់ដូចជា គ្មាន កិច្ច ព្រមព្រៀង ប៉ារីស ថ្ងៃ២៣តុលា ១៩៩១ នេះ ទេ និង ហាក់ បីដូចជាប្រទេសកម្ពុជា ឋិតនៅក្រោម ការត្រួតត្រារបស់យួន តាំងពីពេលដែល ទ័ព យួនចូល មកលុកលុយ កម្ពុជា ពីថ្ងៃ៧មករា១៩៧៩មក។ អ្នកដឹកនាំប្រទេសទាងពីនេះ មើលងាយ ប្រជា ពលរដ្ឋខ្មែរ ដោយ បង្ខិល មតិជាតិ និង អន្តរជាតិ និង ដោយ រំលោភលើកិច្ចព្រមព្រៀងប៉ារីស ថ្ងៃ២៣តុលា១៩៩១ ដែលប្រទេស កម្ពុជា និង ប្រទេសយួន ជាហត្ថលេខី ទៀតផង។ និយាយឱ្យចំ តាមគ្រប់ និយមន័យ ៣៤ ឆ្នាំ ក្រោយ ពីយួនចូលវាតត្បាត និង ២១ ឆ្នាំ ក្រោយពីមានកិច្ចព្រមព្រៀង ប៉ារីស ប្រទេសកម្ពុជាបានក្លាយជាដែនដីយួន រួចអស់ ទៅហើយ។ ពល រដ្ឋ ខ្មែរ បានចាត់ ទុក រដ្ឋមន្ត្រីទី១ ហ៊ុនសែន ជាជន ផ្តាច់ការ និង ជាជនក្បត់ជាតិ មាតុភូមិ។ គេបានចាត់ទុក ប្រទេស វៀត ណាម កុម្មុយនិស្ត ថាជា ប្រទេសឈ្លានពាន ធ្វើ អាណានិគម និង ចក្រពត្តិនិយម លើកម្ពុជា។ ជាបញ្ជប់ តាមភាព ជាក់ស្តែង ពលរដ្ឋខ្មែរ បានចាត់ ទុករាជានិយមទី២ និង រដ្ឋបក្សប្រជាជនហ៊ុនសែន ថាបានក្បត់ជាតិខ្មែរ ។ ជាដាច់ ខាត នៅដើមសតវត្ស ទី២១ នេះ ប្រជាពលរដ្ឋខ្មែរចង់រស់ ក្នុង សេរីភាព ឯករាជ និង មិននៅក្រោមអាណានិគម របស់ យួនទេ។ គឺដូច ជា ប្រជា ពលរដ្ឋយួន ដែលតស៊ូប្រឆាំង បារាំង និង អាមេរិកាំង ក្នុងសតវត្សទី២០ ដូច្នោះដែរ។

ការលុបចោលសន្ធិសញ្ញាទាំងនេះ ត្រូវតែធ្វើឱ្យបានរួចរាល់ចាប់ពីឆ្នាំ១៩៩៣ មកម្ល៉េះ ក្រោយពេលដែល ប្រទេសកម្ពុជា មានស្តេច មានរាជរដ្ឋាភិបាល និង ស្ថាប័ននានា ដូចសភាជាតិ និង ព្រឹទ្ធសភាជាដើម ស្របតាមច្បាប់រដ្ឋធម្មនុញ្ញ។ ក៏ប៉ុន្តែ ដោយអ្នកដឹកនាំ ខ្មែរជាជនក្បត់ជាតិ (មានស្តេច តំណាងរាស្ត្រ រដ្ឋមន្ត្រី, ព្រឹទ្ធសភា,,) ទើបប្រជាជាតិ ពុំទាន់បាន ឃើញ ការលុប ចោល សន្ធិសញ្ញា និង ឯករាជកម្ពុជា នៅឡើយទេ។ ជនក្បត់ ជាតិ ទាំងនេះ នាំគ្នា បង្កើតរាជានិយមទី២ ទាំងកំរោល និង ទាំងបង្ខិតបង្ខំ ដែលសព្វថ្ងៃ អំពើ ក្បត់ ជាតិ របបផ្តាច់ ការ អំពើអយុត្តិធម៌ និង អំពើពុក រលួយ បាន និង កំពុងប្រព្រឹត្តទៅ ដោយគគ្រឹកគគ្រេង គ្មានទារុណភាព ដើម្បីបំរើផល ប្រយោជន៏យួន ឱ្យមានប្រសិទ្ធិភាពប្រសើរ ឡើងៗ។

ដូច្នេះដើម្បីទាមទារឱ្យបានវិញនូវ ឯករាជភាព និង បូរណភាពទឹកដី ប្រជា ពលរដ្ឋ ខ្មែរមាន ជំរើសតែ មួយគត់ គឺធ្វើសង្គ្រាមរំដោះ តាមរយៈបដិវត្តន៏ផ្កាឈូក។ ដើម្បីសំរេចបាន ប្រជាពលរដ្ឋខ្មែរ ត្រូវដេញជន ក្បត់ជាតិ ចេញ ដោយខ្លួនឯង ឱ្យអស់ពីអំណាច ដោយប្រើគ្រប់មធ្យោបាយ ស្របតាម <u>កិច្ចព្រម ព្រៀង ក្រុង ប៉ារីស និង ស្របតាម ការប្រកាសជា សាកលនៃសិទ្ធិមនុស្ស។ គេមិនត្រូវទទួលយក ភាពជាក់ស្តែង ដែល យួនបង្កើត នៅហ្នឹង កន្លែងដូចសព្វថ្ងៃនេះទេ ហើយគេមិនត្រូវសង្ឃឹម</u>

ទុកចិត្តលើអ្នកដឹកនាំរាជាកុម្មុយនិស្តទាំងនេះទៀតដែរ។ ដូច្នេះ បដិវត្តន៍ផ្កាឈូក គឺជាកាតព្វកិច្ច ចាំបាច់ជៀសពុំរួច ដើម្បី រំដោះប្រទេសកម្ពុជា ចេញពីយួន និង រំដោះពលរដ្ឋខ្មែរចេញពីជនផ្តាច់ការ ហ៊ុនសែន។

ឧបករណ៍អន្តរជាតិដ៏សែនមានតំលៃ គឺកិច្ចព្រមព្រៀងប៉ារីស នេះ នឹងក្លាយជាវត្ថុឥតប្រយោជន៍ បើសិនជា ខូបទី២១ នៃកិច្ច ព្រមព្រៀងប៉ារីសមិនបានជំរុញខ្មែរឱ្យ យកមកធ្វើជាឧបករណ៍ សំរាប់រំដោះមាតុភូមិ ទេ។ យោង តាមការប្រកាស ជាសាកលនៃសិទ្ធិមនុស្ស នៃសិទ្ធិប្រជាជាតិ អ្នក បដិវត្តន៍ ផ្កាឈូក មាន សត្រូវ ២ គឺ អ្នកដឹកនាំខ្មែរ ក្បត់ជាតិ និង អ្នក ដឹកនាំយួន អាណានិគមឈ្លានពាន។ គេមានសិទ្ធិបង្ខំឱ្យក្រុម ទាំងពីរនេះ គោរព តាមកិច្ចព្រមព្រៀង ប៉ារីស ថ្ងៃ២៣តុលា ឆ្នាំ ១៩៩១ ។ យើងមិនត្រូវទទួលយក បរាជ័យ ជា ដាច់ខាត។ បើ បដិវត្តន៍ផ្កាឈូក ចាញ់ គឺ ប្រទេស កម្ពុជា និង ប្រជាពលរដ្ឋ ខ្មែរ ទាំងមូលដែលចាញ់យួន និង ចាញ់អំពើផ្តាច់ការបក្សប្រជាជន ហ៊ុនសែន។ បដិវត្តន៍ផ្កាឈូក មានរំពឹង ភាគច្រើនលើ មនសិការជាតិនៃ យុវជន បុគ្គលិកសិក្សា កម្មករ កសិករ បញ្ញវន្ត ទាំងក្រៅ និង ក្នុងប្រទេស កង ប្រដាប់អាវុធ ទាហាន ប៉ូលីស នគរបាល ព្រះសង្ឃ ឧបាសក ឧបាសិការ អ្នកស្រែ អ្នកចំការ អ្នករដ្ឋការ អ្នកជំនួញ ...។ បដិវត្តន៍ ផ្កាឈូក នៅពុំទាន់ ចប់ទេ បើ ខ្មែរពុំទាន់ សំរេចបាននូវ គោលដៅទាំងបី របស់ ជាតិយើង គឺ រំដោះឱ្យបាន នូវ មាតុភូមិ និង រំលំរបបហ៊ុនសែន រួច ហើយ បង្កើត របបសេរី ប្រជាធិបតេយ្យ ពិតប្រាកដ។ យើងសូម អំពាវនាវឱ្យ ប្រជាពលរដ្ឋនៃ បដិវត្តន៍ផ្កាឈូក អនុវត្ត នូវ ស្ម័គ្រមីប្រជាពលរដ្ឋ ជាបន្ទាន់ និង ធំធេង ដោយប្រើ បញ្ញាញាណ និង ប្រើ ការត្រិះរិះ ពិចារណា ដើម្បី សំរបសំរួល ស្ម័គ្រមីប្រជាពលរដ្ឋ ទៅតាមទីកន្លែង។

## *បងប្អូនរួមជាតិជាទីគោរព*

ដើម្បី រំលឹកខួបទី២១ នៃកិច្ចព្រមព្រៀងក្រុងប៉ារីស ថ្ងៃ២៣តុលា១៩៩១ យើងសុំអំពាវនាវ ឱ្យប្រជាពលរដ្ឋខ្មែរនាំគ្នា ធ្វើ បាតុកម្ម តាមគ្រប់មធ្យោបាយ ឱ្យបានគគ្រឹកគគ្រេង និង ធំធេង នៅគ្រប់ទីកន្លែង ដើម្បីសំរេច ឱ្យបាន នូវការរំដោះ ប្រទេស កម្ពុជា និង រំដោះប្រជាពលរដ្ឋខ្មែរ។ យើង សូមប្រសិទ្ធិពរ ឱ្យការហែរក្បួន នៃប្រជាពលរដ្ឋ នៅថ្ងៃ២៣តុលា ២០១២ ដៃកាន់ធូបនិងផ្កាឈូក ដើម្បី បង្ខំឱ្យយួនអាណានិគម ចាកចេញពីទឹកដីខ្មែរ និង បញ្ចប់អំពើផ្តាច់ការ រាជា កុម្មុយនិស្ត បក្ស ប្រជាជន ហ៊ុនសែន ឱ្យ បាន សំរេច។ ដើម្បីការពារ បូរណ ភាពទឹកដី ប្រជា ពលរដ្ឋ ខ្មែរ មិនត្រូវសង្ឃឹម លើ អ្នកដឹកនាំខ្លួនសព្វថ្ងៃទៀតទេ ហើយនឹង មិនត្រូវ ជឿ លើពាក្យសន្យា នៃអ្នកទាំងនោះ នាពេលបោះឆ្នោតរើសសភាខាងមុខ នេះ ឡើយ។ ព្រោះ សព្វថ្ងៃ ប្រព័ន្ធ នៃគណបក្សនយោបាយនៅកម្ពុជា ពុំបំរើប្រយោជន៍ឱ្យ អ្នកបោះឆ្នោត ឬ ប្រជាពលរដ្ឋទេ គឺ សំរាប់បំរើ តែ គណបក្ស នយោបាយ និង មេដឹកនាំ តែប៉ុន្នោះ។ គឺវាជាការខាត ពេល ទៀតហើយ។ គេត្រូវ តែជំរុញបង្ខំ តាមគ្រប់ មធ្យោ បាយ ឱ្យ ប្រទេសកម្ពុជា (ជំពូក១) និង ប្រទេស យួន (ជំពូក២) លុប ចោលជាបន្ទាន់ នូវ សន្ធិសញ្ញា ១៩៧៩ ១៩៨២ ១៩៨៣ ១៩៨៥ និង សន្ធិសញ្ញា បំពេញបន្ថែម ២០០៥។ គេមានសិទ្ធិធ្វើ បែបនេះ។ ប្រទេសហត្ថលេខីទាំង១៧ គ្មានសិទ្ធិជំទាស់ទេ តែផ្ទុយទៅវិញ ប្រទេសទាំងនេះមាន ករណីយកិច្ច ជួយពលរដ្ឋខ្មែរទៀតផង (ជំពូក៤)។

### *ទង្វើខ្លះៗដែលត្រូវអនុវត្ត៖*

- ដុត ទង់ជាតិយួន និង ដុត សន្ធិសញ្ញា ១៩៧៩ ១៩៨២ ១៩៨៣ ១៩៨៥ និង សន្ធិសញ្ញាបំពេញបន្ថែម២០០៥ ជា និមិត្តរូប ដោយសន្តិវិធី តែក្នុងភាពម៉ឺងម៉ាត់ បង្ហាញពីការសុំលុបចោលជាបន្ទាន់នូវសន្ធិសញ្ញាដ៏អយុត្តិធម៌ទាំងនេះ (ជំពូក១)។

ពីព្រោះថា អ្នកដឹកនាំខ្មែរទាំងអស់ មាន សមរង្សី កែមសុខា ជាដើម ពុំដែលហ៊ានសុំឱ្យច្បាស់ៗ លុបចោល សន្ធិសញ្ញា ទាំងនេះ ជាលាយល័ក្ខអក្សរទេ។ គេនាំគ្នាគាំទ្រ សីហនុ ដែលចង់ឱ្យ មានការវិលត្រឡប់នៃរាជានិយមទី២ មកវិញជាដាច់ខាត ទោះនៅ ក្នុងលក្ខ័ណ្ឌណាក៏ដោយ។ ហើយ សីហនុ គាំទ្រ ហ៊ុនសែន និង បក្សប្រជាជន។ ដោយ ហ៊ុនសែន និង បក្សប្រជាជន ជាអាយ៉ង យួន ហើយ ក្ដោបអំណាចគ្រប់បែបយ៉ាងទាំងអស់ ដូច្នេះ អ្នកដឹកនាំខ្មែរទាំងអស់ រួមទាំងស្ដេចផង ត្រូវតែនាំគ្នាគាំទ្រនយោបាយយួន ដែលកាត់យកទឹកដីខ្មែរ។ ហេតុយ៉ាងនេះហើយ បានជា ប្រទេសកម្ពុជាកំពុងតែបាត់បង់បូរណភាព ទឹកដី និង ឯករាជ្យជាបន្តទៀត (ផ្ទុយពី ជំពូក១)។

-ប្រកាសឱ្យអាណិកជនយួន ជាស៊ីវិល និង ទាហាន ដែលរស់នៅក្នុងស្រុកខ្មែរ បានដឹងថា គេនឹងអាចទទួលរងគ្រោះថ្នាក់ធំ ធ្ងន់ធ្ងរ នៅចំពោះមុខច្បាប់ ស្ដីពីអន្តោប្រវេសន៍ដែលអនុម័តដោយសភាជាតិខ្មែរ។

-បង្ខំ យួនចក្រពត្តិ ដែល ជាហត្ថលេខីនៃកិច្ចព្រមព្រៀងប៉ារីសដែរនោះ ឱ្យលុបចោលជាបន្ទាន់ នូវសន្ធិសញ្ញាទាំងនេះ ហើយ ដកចេញនូវកងទ័ពវាជាង ១សែននាក់ ដែលក្លែងខ្លួនជាភ្នាក់ងារស៊ីវិលចូលមកវិញ បន្លំលាក់ខ្លួននៅក្នុងប្រទេសកម្ពុជា (ជំពូក២)។

-ផ្ដល់ដំណឹងឱ្យ អសប ដែលជា អ្នកផ្ដួចផ្ដើមឱ្យមានសន្និសិទក្រុងប៉ារីសថ្ងៃ២៣តុលា១៩៩១ និង ក្រុមប្រឹក្សាសន្តិសុខពីការ ដែល យួន និង ខ្មែរមិនគោរពកិច្ចព្រមព្រៀងនេះ ហើយ ជូន ពត៌មានឱ្យគេបានដឹងជាមុន ពីការដែលអាចមាន ភាពជ្រួលជ្រួស នានា ជា យថាហេតុ ដែល នឹងអាច កើត ឡើង ពី កំហឹងនៃ ជនជាតិខ្មែរ ដែល ឃើញជនជាតិយួន នៅបន្តកាត់យកទឹកដី និង មកតាំងទី លំនៅ កាន់តែច្រើនឡើងៗ ទាំងស៊ីវិល ទាំង ទាហហាន (ពី ៥ ទៅ ៧ លាននាក់?) នៅកម្ពុជា ។ ផ្ដល់ដំណឹង ឱ្យសហគមន៍ អន្តរជាតិ និង សមាជិកនៃអសប ពីផលវិបាកដ៏ធ្ងន់ធ្ងរ ដែលអាចជា គ្រោះថ្នាក់លើ អស្ថេរភាព និង អសន្តិសុខ នៅក្នុងតំបន់ ដែលអាចកើតឡើង ដោយសារ ការមិនគោរព កិច្ច ព្រមព្រៀងនេះ ដោយយួន និង ខ្មែរ( ជំពូក៥)។

-ប្រជាពលរដ្ឋខ្មែរ ត្រូវតែប្រតិកម្មយ៉ាងខ្លាំងក្លា គ្មានឈប់ឈរ គ្រប់ទីកន្លែង នៅអសប នៅមុខស្ថានទូត ខ្មែរ យួន នៅស្រុកខ្មែរ និង នៅបរទេស ។ បាតុកម្ម ដោយសន្តិវិធី តែដោយចិត្តមុះមុត ស្របតាមស្មារតី នៃកិច្ចព្រមព្រៀងប៉ារីស នឹងត្រូវបញ្ចប់នៅពេលណាដែល យួន និង ខ្មែរបានលុបចោលរួចរាល់ ជាស្ថាពរ នូវសន្ធិសញ្ញានេះ និង ពេលណាដែលខ្មែរគោរព អនុវត្តពេញលេញនូវ ជំពូក៣ នៃកិច្ចព្រមព្រៀងប៉ារីសស្ដីពីសិទ្ធិមនុស្ស។ រដ្ឋាភិបាលបណ្ដោះអាសន្នមួយ នឹង ត្រូវកើតឡើងដើម្បី រៀបចំ ឱ្យមាន ស្ថាប័នតំណាងជាតិ ហើយ ផ្ដល់ឱកាសឱ្យពលរដ្ឋ ជ្រើសរើស យក របបសេរី មួយ តាមលទ្ធិ ប្រជាធិបតេយ្យ និង មានសិទ្ធិ រើស អ្នកដឹកនាំ ដោយសេរី។ នៅមុនការទទួលបាននូវ ជោគជ័យរួម សំរាប់ជាតិ និង ដោយប្រជាពលរដ្ឋការបោះឆ្នោត ទាំងឡាយ នឹង គ្រាន់តែ ជា ការបន្លំភ្នែក ការក្បៀបសង្កត់ បង្ខិតបង្ខំ និង អំពើក្បត់ជាតិ តែប៉ុណ្ណោះ។

## *បងប្អូនរួមជាតិជាទីគោរព*

យើងសូមរំលឹកថា ជានិច្ចជាកាល ប្រទេសយួនព្រហើនណាស់ ។ សព្វថ្ងៃ វាហ៊ានបន្តការកាត់យកទឹកដី និង ប្រព្រឹត្តអំពើចក្រពត្តិ មកលើប្រទេសកម្ពុជា ក៏ព្រោះតែ ក្រោយពី ប្រទេសបារាំង កាត់ដែនដីកុសាំងស៊ីន ឱ្យយួន នៅថ្ងៃ៤ មិថុនា ១៩៤៩ មក រាជាណាចក្រទី១ របស់ សីហនុ មិនដែលហ៊ាន ប្រតិកម្មខ្លាំងក្លាទេ ដោយខ្លាច បាត់បង់រាជបល្ល័ង្កដែលបារាំងប្រគល់ឱ្យ។ បច្ចុប្បន្ននេះ ខ្មែរ នៅ កម្ពុជាក្រោមដែលរងគ្រោះ កំពុងតែធ្វើការតស៊ូនិងទាមទារ យកឯករាជ្យពីយួនដោយ គ្មានជំនួយ ពីមាតុប្រទេសទេ ហើយ ក៏គ្មាន ជំនួយពីសីហនុ ដែលជាអ្នកទទួលខុសត្រូវ លើការបោះបង់ចោលទឹកដីដ៏អាម៉ាស់

នេះផងដែរ។ វា ដូចគ្នាបេះបិទទៅអ្វីៗដែលកើត មាន នាពេលបច្ចុប្បន្ននេះ គឺ សីហនុ និង គ្រួសារ បានសុំឱ្យ ស្តេចសីហមុនី ស៊ីញ៉េសន្ធិសញ្ញា បំពេញបន្ថែម ២០០៥ ក្រោមការកៀបសង្កត់ ពីហ៊ុនសែន អាយ៉ងយួន ព្រោះតែខ្លាចបាត់បង់រាជសម្បត្តិ នៃរាជាណាចក្រទី២ ដែលសព្វថ្ងៃនេះ បានទទួលលុយ ប្រមាណជា ១៥លាន ដុល្លា សហរដ្ឋអាមេរិក ជារៀងរាល់ឆ្នាំ ពីរដ្ឋ អាយ៉ង បក្សប្រជាជន ដើម្បីត្រដរ រស់ កុំឱ្យស្លាប់ ។ ជ័យជំនះ បដិវត្តន៍ផ្កាឈូក គឺដើម្បីប្រទេសកម្ពុជា និង ប្រជាពលរដ្ឋខ្មែរ មិនមែនដើម្បី គណបក្ស ណាមួយ ឬ បុគ្គល ណាមួយទេ ។ ដោយមានជំនួយ ពីបក្សប្រជាជនអាយ៉ង នេះ ហើយ បានជា យួននៅតែហ៊ានតទល់ដោយព្រហើន ប្រឆាំង សហគមន៍ អន្តរជាតិ បន្តរក្សាសុពលភាពនៃសន្ធិសញ្ញាអយុត្តិធម៌ ឆ្នាំ ១៩៧៩ ១៩៨២ ១៩៨៣ ១៩៨៥ ហើយ ដាក់បង្ខំឱ្យ ខ្មែរ អនុវត្ត សន្ធិសញ្ញា បំពេញបន្ថែម២០០៥ ទៀត ដើម្បីលេបយកទឹកដីខ្មែរ តាម ស្បៀត និង តាម ល្បិចកល ហាក់បីដូចជា ពិភពលោក ពុំបាន ធ្វើកិច្ចព្រមព្រៀងប៉ារីស ថ្ងៃទី២៣តុលា១៩៩១ នេះទេ។ ព្រោះ ហេតុនេះហើយ បានជា បក្សប្រជាជន លុបទិវាជាតិថ្ងៃ២៣តុលា ដើម្បីរំលឹកកិច្ចព្រមព្រៀងប៉ារីសឆ្នាំ១៩៩១ ចោល ហើយបែរជាធ្វើពិធីអបអរ សាទរ ថ្ងៃ៧ មករា ដើម្បី រំលឹកជោគជ័យយួន មិន ហ៊ានចាត់ទុកថ្ងៃនេះ ថាជា អំពើដែលយួន វាតទ្បាតប្រទេសកម្ពុជា ទេ។


អ៊ូ ចល

សមាជិកស្ថាបនិក- បដិវត្តន៍ផ្កាឈូក

*(http:/www.khmerlotusrevolution.com)*

បណ្ឌិតទស្សនវិជ្ជា សាកលវិទ្យាល័យស័របោន ប៉ារីស

DEA de Philosophie- Sorbonne Paris

បណ្ឌិតពត៌មានវិទ្យាឯកសារ សាកលវិទ្យាល័យលីយ៉ុង១ និង អិនស៊ីប

DESS Informatique Documentaire- Lyon I & ENSSIB


*****************************************************************